ក

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៦-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៣៨ ស្តីពី ការតែងតាំង លោក អ៊ឹង គួនអៃ ជាឧកញ៉ា ៧៨៨០

២២-៩-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៩១០/៧៧៣ ស្តីពី ការបំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា តាមឋានានុក្រម ដល់ សមាជិក សមាជិកា រដ្ឋសភានីតិកាលទី ៤ លើកទី ១ ចំនួន ១១៦ រូប ៧៨៨១

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

៣០-៩-២០១០ -អនុក្រឹត្យលេខ ៩៩៥ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៨៨៩

៣០-៩-២០១០ -អនុក្រឹត្យលេខ ៩៩៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៨៩០

២. សេចក្តីសម្រេច

៣០-៩-២០១០ -សេចក្តីសម្រេចលេខ ៤៩ សសរ ស្តីពី ការបង្កើតគណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ ៧៨៩១

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ & ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

២៣-៩-២០១០ -ប្រកាសរួមលេខ ៧១៥/៥៨៥ ប្រក.សហវ.កសក ស្តីពី ការកែសម្រួលប្រការ ២ នៃប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ ៧៨៩៣

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៧-៩-២០១០ -ប្រកាសលេខ ៧១៨ សហវ. ប្រក ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សម្របសម្រួលការងារជួសជុល-ថែទាំផ្លូវជនបទ ៧៨៩៥

២៧-៩-២០១០ -ប្រកាសលេខ ៧១៩ សហវ. ប្រក ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សម្របសម្រួលការងារជួសជុល-ថែទាំប្រព័ន្ធធារាសាស្ត្រ ៧៨៩៨

២២-៩-២០១០ -សេចក្ដីសម្រេចលេខ ០៣៣ សហវ ស្ដីពី ការបង្កើតក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស ៧៩០១

៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

២០-៨-២០១០ -ប្រកាសលេខ ៥៤៨ ប្រក.កសក ស្ដីពី ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ ក្នុងខេត្តកែប ៧៩០៤

៤_ទីស្ដីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

២៧-៩-២០១០ -សេចក្ដីសម្រេចលេខ ៤៩ សសរ.អកគដ ស្ដីពី ការដាក់ឱ្យប្រើប្រាស់គំរូឧបសម្ព័ន្ធដើម្បីអនុវត្តសារាចរស្ដីពីការដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្រ្ទានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និង ទីប្រជុំជន ៧៩០៩

៥_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០១៥៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ីង ម៉េងគីត ខូ អិលធីឌី ៧៩៣៤

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០១៥៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន នៀង គួយ ៧៩៣៦

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០១៦០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ត្លាមគ្រហម វ៉ៃតួសាន បេស 59 ៧៩៣៨

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០១៦១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ម៉ិន ម៉ាលី អ៊ីមផត អិចផត ខូ អិលធីឌី ៧៩៤០

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០១៦៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន សាយហ្គនរថគ ត្លាស (ខេមបូឌា) ខបតើរេសិន ៧៩៤២

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០១៦៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហេង ហ៊ែនរី អ៊ិនធើណេសិនណាល ៧៩៤៤

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក អ៊ឹង គួងហៃ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៧.១០០៩.៦៥៣

នរោត្តម សីហមុនី

លេខៈ ៧/១១ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១០

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩១០/៧៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គល សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស.រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា

ត្រាស់បង្គាប់

មាត្រា ១. បំពាក់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជាតាមឋានានុក្រមដល់ សមាជិក សមាជិកា រដ្ឋសភានីតិកាលទី៤ លើកទី១ចំនួន ១១៦ រូប ដូចមានរាយនាមខាងក្រោម ៖

ក- គ្រឿងឥស្សរិយយស **ជាតូបការ**

១-	សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម ប្រធានរដ្ឋសភា
២-	សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**	តំណាងរាស្ត្រមណ្ឌលកណ្តាល សមាជិកសាមញ្ញ
៣-	សម្តេចចៅហ្វាវាំង **គង់ សំអុល**	តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង សមាជិកសាមញ្ញ
៤-	ឯកឧត្តម **ងួន ញ៉ិល**	តំណាងរាស្ត្រមណ្ឌលកំពង់ធំ អនុប្រធានទី១ រដ្ឋសភា
៥-	ឯកឧត្តម **អ៊ុន នឹង**	តំណាងរាស្ត្រមណ្ឌលកំពង់ធំ ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ
៦-	ឯកឧត្តម **ប៉ែន បញ្ញា**	តំណាងរាស្ត្រមណ្ឌលព្រៃវែង ប្រធានគណៈកម្មការនីតិកម្ម និង យុត្តិធម៌
៧-	លោកជំទាវ **និន សាផុន**	តំណាងរាស្ត្រមណ្ឌលតាកែវ ប្រធានគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៨- ឯកឧត្តម **ស ខេង**	តំណាងរាស្ត្រមណ្ឌលបាត់ដំបង សមាជិកសាមញ្ញ
៩- ឯកឧត្តម **នៃ ប៉េណា**	តំណាងរាស្ត្រមណ្ឌលកំពត សមាជិកសាមញ្ញ
១០- ឯកឧត្តម **ម៉ូ ថង**	តំណាងរាស្ត្រមណ្ឌលរតនគីរី សមាជិកសាមញ្ញ

ខ- គ្រឿងឥស្សរិយយស **ឯករាជជាតិ**

១- ឯកឧត្តម **សាយ ឈុំ**	តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ អនុប្រធានទី២ រដ្ឋសភា
២- ឯកឧត្តមបណ្ឌិតរដ្ឋ **ចាម យៀប**	តំណាងរាស្ត្រមណ្ឌលព្រៃវែង ប្រធានគណៈកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៣- ឯកឧត្តម **សុខ អាន**	តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកសាមញ្ញ
៤- ឯកឧត្តម **ហោ ណាំហុង**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកសាមញ្ញ
៥- ឯកឧត្តម **គាត ឈន់**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកសាមញ្ញ
៦- ឯកឧត្តម **ទៀ បាញ់**	តំណាងរាស្ត្រមណ្ឌលសៀមរាប សមាជិកសាមញ្ញ
៧- ឯកឧត្តម **ញឹម វណ្ណដា**	តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកសាមញ្ញ
៨- ឯកឧត្តម **ជា សុទ្ធ**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកសាមញ្ញ

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- លោកជំទាវ **ឃួន សុដារី**	តំណាងរាស្ត្រមណ្ឌលកណ្តាល ប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និង ទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា
២- ឯកឧត្តម **ទ្រី ឈានហ៊ួត**	តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ ប្រធានគណៈកម្មការ ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និង ធនធានទឹក
៣- ឯកឧត្តម **ឈាង វុន**	តំណាងរាស្ត្រមណ្ឌលបាត់ដំបង ប្រធានគណៈកម្មការកិច្ចការ បរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៤- ឯកឧត្តម **ហែម ខន**	តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ អនុប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការ សាសនា វប្បធម៌ និងទេសចរណ៍
៥- ឯកឧត្តម **ហ៊ី ស្រ៊ី**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ លេខាធិការគណៈកម្មការកិច្ចការ បរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៦- ឯកឧត្តម **ស៊ុក សំអេង**	តំណាងរាស្ត្រមណ្ឌលព្រះវិហារ សមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
៧- ឯកឧត្តម **មុយ ចាត**	តំណាងរាស្ត្រមណ្ឌលបាត់ដំបង សមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨- ឯកឧត្តម **ប៊ិន ឈិន**	តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកសាមញ្ញ
៩- ឯកឧត្តម **យឹម នៃលី**	តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ សមាជិកសាមញ្ញ
១០- ឯកឧត្តម **សំរិត ម៉ិច**	តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ សមាជិកសាមញ្ញ
១១- លោកជំទាវ **សោម គឹមសួគ៌**	តំណាងរាស្ត្រមណ្ឌលកំពត សមាជិកាសាមញ្ញ

ឃ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- លោកជំទាវ **ហូ ណុន**	តំណាងរាស្ត្រមណ្ឌលកណ្តាល ប្រធានគណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិ សម្បទា ការងារបណ្តុះបណ្តាល វិជ្ជាជីវៈ និងកិច្ចការនារី
២- ឯកឧត្តម **មីន ស៊ាន**	តំណាងរាស្ត្រមណ្ឌលព្រៃវែង អនុប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិ សម្បទា ការងារបណ្តុះបណ្តាល វិជ្ជាជីវៈ និងកិច្ចការនារី
៣- ឯកឧត្តម **ចាយ បូរិន**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៤- ឯកឧត្តម **យូ ហុកគ្រី**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកសាមញ្ញ
៥- ឯកឧត្តម **សុន ឆ័យ**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកសាមញ្ញ

ង- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម **សោម ចិន**	តំណាងរាស្ត្រមណ្ឌលកំពត អនុប្រធានគណៈកម្មការសាធារណការដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់
២- ឯកឧត្តម **សៀង ណាំ**	តំណាងរាស្ត្រមណ្ឌលសៀមរាប សមាជិកសាមញ្ញ

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១- ឯកឧត្តម **ប៉ាល់ សំអឿន**	តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ អនុប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ
២- លោកជំទាវ **អ៊ឹម រុន**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម អនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៣- ឯកឧត្តម **ស៊ិក ប៊ុនហុក**	តំណាងរាស្ត្រមណ្ឌលកំពង់ធំ អនុប្រធានគណៈកម្មការ នីតិកម្ម និងយុត្តិធម៌
៤- លោកជំទាវ **លី គឹមលៀង**	តំណាងរាស្ត្រមណ្ឌលបាត់ដំបង លេខាធិការគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៥- ឯកឧត្តម **ចៅ សុផុន**	តំណាងរាស្ត្រមណ្ឌលតាកែវ លេខាធិការគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ
៦- លោកជំទាវ **ឈុន សារីម**	តំណាងរាស្ត្រមណ្ឌលស្វាយរៀង សមាជិកាគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៧- ឯកឧត្តម **ខែក សំអុន**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៨- ឯកឧត្តម **ឈឹម ម៉ា**	តំណាងរាស្ត្រមណ្ឌលសៀមរាប សមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៩- ឯកឧត្តម **សួស អាណាន**	តំណាងរាស្ត្រមណ្ឌលព្រះសីហនុ សមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
១០- លោកជំទាវ **ជួន វណ្ណា**	តំណាងរាស្ត្រមណ្ឌលស្វាយរៀង សមាជិកាគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
១១- ឯកឧត្តម **ហ៊ុល សាវ័ន្ត**	តំណាងរាស្ត្រមណ្ឌលស្វាយរៀង សមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ
១២- ឯកឧត្តម **យស់ សុន**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកគណៈកម្មការកិច្ចការ បរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
១៣- ឯកឧត្តម **អ៊ុំ ញ៉ាញ់**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកគណៈកម្មការកិច្ចការ បរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
១៤- ឯកឧត្តម **លី សុន**	តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ សមាជិកគណៈកម្មការនីតិកម្ម និងយុត្តិធម៌
១៥- លោកជំទាវ **ជួញ សុនៃ**	តំណាងរាស្ត្រមណ្ឌលបាត់ដំបង សមាជិកាគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិ សម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
១៦- ឯកឧត្តម **ប្រាក់ នុច**	តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិ សម្បទា ការងារបណ្តុះបណ្តាល វិជ្ជាជីវៈ និងកិច្ចការនារី
១៧- ឯកឧត្តម **វ៉ុត សារ៉ែម**	តំណាងរាស្ត្រមណ្ឌលមណ្ឌលគិរី សមាជិកសាមញ្ញ
១៨- ឯកឧត្តម **សម ខៀវ**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកសាមញ្ញ
១៩- លោកជំទាវ **ជូឡុង សូម្ភូរ៉ា**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកាសាមញ្ញ
២០- ឯកឧត្តម **គីមសួរ ភីរិទ្ធ**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកសាមញ្ញ

ឆ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១- ឯកឧត្តម **អោយ ខន** តំណាងរាស្ត្រមណ្ឌលកោះកុង អនុប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

២- ឯកឧត្តម **ជិន គីមស្រេង** តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់

៣- ឯកឧត្តម **យឹម សុវណ្ណ** តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកសាមញ្ញ

ជ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា**

១- ឯកឧត្តម **ញ៉ែម ថ្ងាវី** តំណាងរាស្ត្រមណ្ឌលកំពង់ធំ លេខាធិការគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

ឈ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

១- ឯកឧត្តម **ម៉ាន់ សេងលី** តំណាងរាស្ត្រមណ្ឌលកំពង់ចាម អនុប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

២- លោកជំទាវ **គ្រួច សំអាន** តំណាងរាស្ត្រមណ្ឌលភ្នំពេញ លេខាធិការគណៈកម្មការ នីតិកម្ម និងយុត្តិធម៌

៣- លោកជំទាវ **ត្រឹង ថាវី** តំណាងរាស្ត្រមណ្ឌលក្រចេះ លេខាធិការគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការ សាសនា វប្បធម៌ និងទេសចរណ៍

៤- លោកជំទាវ **ពៅ សាឡឿន** តំណាងរាស្ត្រមណ្ឌលសៀមរាប លេខាធិការគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិ សម្បទាការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

៥- ឯកឧត្តម **សំ ហ៊ាង** តំណាងរាស្ត្រមណ្ឌលសៀមរាប លេខាធិការគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់

៦- ឯកឧត្តម **សន អ៊ិនថរ** តំណាងរាស្ត្រមណ្ឌលស្ទឹងត្រែង សមាជិកគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

៧- លោកជំទាវ **ចែម សាវ៉ៃ** តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកាគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ

៨- ឯកឧត្តម **អាន ហោ** តំណាងរាស្ត្រមណ្ឌលកែប សមាជិកគណៈកម្មការ នីតិកម្ម និងយុត្តិធម៌

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៩- ឯកឧត្តម **ឆេស ម៉ារ៉ាញ** តំណាងរាស្ត្រមណ្ឌលបាត់ដំបង សមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការ សាសនា វប្បធម៌ និងទេសចរណ៍

១០- ឯកឧត្តម **នៅ សំ** តំណាងរាស្ត្រមណ្ឌលឧត្តរមានជ័យ សមាជិកសាមញ្ញ

១១- ឯកឧត្តម **ជា ប៉ូច** តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកសាមញ្ញ

១២- លោកជំទាវ **ថាក់ ឡានី** តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកាសាមញ្ញ

១៣- ឯកឧត្តម **គួយ ប៊ុនរឿន** តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកសាមញ្ញ

១៤- ឯកឧត្តម **ម៉ៅ មុនីវណ្ណ** តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកសាមញ្ញ

១៥- លោកជំទាវ **កែ សុវណ្ណរតន៍** តំណាងរាស្ត្រមណ្ឌលសៀមរាប សមាជិកាសាមញ្ញ

១៦- ឯកឧត្តម **នុត រុំដួល** តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ សមាជិកសាមញ្ញ

១៧- ឯកឧត្តម **អេង ឆៃអ៊ាង** តំណាងរាស្ត្រមណ្ឌលបាត់ដំបង សមាជិកសាមញ្ញ

ញ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

១- ឯកឧត្តម **ញឹក ប៊ុនឆៃ** តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ សមាជិកសាមញ្ញ

២- ឯកឧត្តម **ជាម ច័ន្ទនី** តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកសាមញ្ញ

៣- ឯកឧត្តម **ចាន់ ចេង** តំណាងរាស្ត្រមណ្ឌលកណ្តាល សមាជិកសាមញ្ញ

៤- ឯកឧត្តម **ហួរ ង៉ាន់** តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកសាមញ្ញ

ដ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

១- ឯកឧត្តម **សាខ្សេះ សេន** តំណាងរាស្ត្រមណ្ឌលកំពត សមាជិកគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

២- ឯកឧត្តម **ងៀប ស៊ីវន** តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

៣- លោកជំទាវ **យ៉ាន ហុនលី** តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកាគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

៤- ឯកឧត្តម **អន ស៊ុំ** តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ សមាជិកគណៈកម្មការ មហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ

៥- ឯកឧត្តម **សៅ រ៉ានី** តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ

៦- ឯកឧត្តម **នឹម ច័ន្ទតារា** តំណាងរាស្ត្រមណ្ឌលកំពត សមាជិកគណៈកម្មការកិច្ចការ បរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

៧- ឯកឧត្តម **អ៊ិច សារុ** តំណាងរាស្ត្រមណ្ឌលប៉ៃលិន សមាជិកគណៈកម្មការនីតិកម្ម និងយុត្តិធម៌

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៨-	ឯកឧត្តម **អ៊ុក ដាមរី**	តំណាងរាស្ត្រមណ្ឌលកណ្តាល សមាជិកគណៈកម្មការនីតិកម្ម និងយុត្តិធម៌
៩-	ឯកឧត្តម **ហ្សាការីយ៉ា អាដាម**	តំណាងរាស្ត្រមណ្ឌលកណ្តាល សមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការ សាសនា វប្បធម៌ និងទេសចរណ៍
១០-	ឯកឧត្តម **សៅ ឡេង**	តំណាងរាស្ត្រមណ្ឌលស្វាយរៀង សមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការ សាសនា វប្បធម៌ និងទេសចរណ៍
១១-	ឯកឧត្តម **ត្រេស សារ៉ុម**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិ សម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
១២-	លោកជំទាវ **កែ ច័ន្ទមុនី**	តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង សមាជិកាគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និង សំណង់
១៣-	ឯកឧត្តម **អ៊ុំ សុខន**	តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់
១៤-	ឯកឧត្តម **ខួន ស៊ីមអាន**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកសាមញ្ញ
១៥-	លោកជំទាវ **អ៊ឹម សារឿន**	តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ សមាជិកាសាមញ្ញ
១៦-	ឯកឧត្តម **ភាធី តូយ៉េប**	តំណាងរាស្ត្រមណ្ឌលក្រចេះ សមាជិកសាមញ្ញ
១៧-	លោកជំទាវ **ឡុង សាខន**	តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកាសាមញ្ញ
១៨-	ឯកឧត្តម **គឹម សុខា**	តំណាងរាស្ត្រមណ្ឌលកំពង់ចាម សមាជិកសាមញ្ញ
១៩-	ឯកឧត្តម **ឃី វណ្ណាដេត**	តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង សមាជិកសាមញ្ញ
២០-	លោកជំទាវ **មួរ សុខហួរ**	តំណាងរាស្ត្រមណ្ឌលកំពត សមាជិកាសាមញ្ញ
២១-	ឯកឧត្តម **ឃឹម ឡាគី**	តំណាងរាស្ត្រមណ្ឌលកណ្តាល សមាជិកសាមញ្ញ
២២-	ឯកឧត្តម **អ៊ូ ច័ន្ទឫទ្ធិ**	តំណាងរាស្ត្រមណ្ឌលកណ្តាល សមាជិកសាមញ្ញ
២៣-	លោកជំទាវ **ពត ពៅ**	តំណាងរាស្ត្រមណ្ឌលកណ្តាល សមាជិកាសាមញ្ញ
២៤-	ឯកឧត្តម **យន្ត ថារូ**	តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ សមាជិកសាមញ្ញ
២៥-	ឯកឧត្តម **ជីវ កត្តា**	តំណាងរាស្ត្រមណ្ឌលបាត់ដំបង សមាជិកសាមញ្ញ
២៦-	ឯកឧត្តម **ឡុង រី**	តំណាងរាស្ត្រមណ្ឌលក្រចេះ សមាជិកសាមញ្ញ
២៧-	លោកជំទាវ **លី ស្រីវីណា**	តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកាសាមញ្ញ
២៨-	ឯកឧត្តម **គង់ បូរ៉ា**	តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកសាមញ្ញ

ROYAUME DU CAMBODGE * MINISTÈRE DU PALAIS ROYAL *

២៩- ឯកឧត្តម **យ៉េម បុញ្ញឫទ្ធិ** តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកសាមញ្ញ

៣០- ឯកឧត្តម **គុ ស៊ាន់ចាន់** តំណាងរាស្ត្រមណ្ឌលតាកែវ សមាជិកសាមញ្ញ

៣១- ឯកឧត្តម **ម៉ែន សុថាវរិន្ទ្រ** តំណាងរាស្ត្រមណ្ឌលកំពង់ធំ សមាជិកសាមញ្ញ

៤- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១- ឯកឧត្តម **សុខ ឥសាន** តំណាងរាស្ត្រមណ្ឌលព្រៃវែង សមាជិកគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

២- លោកជំទាវ **ឡោក ខេង** តំណាងរាស្ត្រមណ្ឌលភ្នំពេញ សមាជិកាគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិ សម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

៣- ឯកឧត្តម **កែវ សុសាក់** តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង សមាជិកគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់

៤- ឯកឧត្តម **គុជ ម៉ូលី** តំណាងរាស្ត្រមណ្ឌលកំពង់ធំ សមាជិកគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់

មាត្រា ២. សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣. ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល. ១០០៩. ៧៤៩

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១០

លេខ:៧៦៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ តុលា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៩៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ ជូនមន្ត្រីចិន ចំនួន ០៣រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមចំណែកការងារសាងសង់អគារថ្មី នៃទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម៖

1-Mr. LEI PENGQIN	Attache of the Embassy of the People's Republic of China to the Kingdom of Cambodia
2-Ms. GAO YUANYUAN	Vice Director of Department of Aid to Foreign Countries of the Ministry of Commerce of People's Republic of China
3-Mr. LI YAOHUI	Chief of Division of the Department of Aid to Foreign Countries of the Ministry of Commerce of People's Republic of China

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៩៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ជូនបុគ្គលិកក្រុមហ៊ុន China Yunnan Construction Engineering Group Co., Ltd ចំនួន ០២រូប ដែលមានស្នាដៃល្អ ក្នុងការ សាងសង់អគារថ្មី នៃទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម៖

1- Mr. Ma De — Assistant General Manager

2- Mr. Sun Peixi — Deputy Chief Engineer

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៩. សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ ដែលមានសមាសភាពដូចមានរាយនាមខាងក្រោម ÷

១. ឯកឧត្តម	**ស៊ុន ចាន់ថុល**	ទេសរដ្ឋមន្ត្រី និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	ប្រធាន
២. ឯកឧត្តម	**ត្រាំ អ៊ីវតឹក**	រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន
៣. ឯកឧត្តម	**គង់ វិបុល**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៤. ឯកឧត្តម	**ឡុង វិសាលោ**	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៥. ឯកឧត្តម	**សក់ សេដ្ឋា**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៦. ឯកឧត្តម	**តឹករ៉ែត សំរេច**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧. ឯកឧត្តម	**ឈួន ដារ៉ា**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
៨. ឯកឧត្តម	**ប៉ែន ស៊ីម៉ន**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ	សមាជិក

៩. ឯកឧត្តម	**ហួន សាវ៉ាង**	អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការព្រំដែន	សមាជិក
១០. ឯកឧត្តម	**អ៊ុង អឿន**	អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ	សមាជិក។

ប្រការ ២.-

គណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ មានភារកិច្ចដូចខាងក្រោម ÷

- សហការ និងសម្របសម្រួលជាមួយភាគីថៃ ក្នុងដំណើរការរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ ដែលមានទីតាំងស្ថិតនៅក្នុងភូមិស្ទឹងបត់ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីសម្រួលដល់ដំណើរការដឹកទំនិញឆ្លងកាត់គ្រប់ប្រភេទ
- ពិនិត្យ និងកំណត់ចំណុចទីតាំងដែលត្រូវបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងទីតាំងដែលត្រូវសាងសង់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារ
- ធ្វើរបាយការណ៍ និងលើកយោបល់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

ប្រការ ៣.-

សមាជិកគណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងអាចប្រើប្រាស់មន្ត្រីក្នុងអង្គភាពរបស់ខ្លួនបន្ថែមទៀតាមសំណូមពរ និងទំហំការងារជាក់ស្តែង។

ប្រការ ៤.-

គណៈកម្មការចម្រុះដើម្បីរៀបចំបើកច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ប្រការ ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
លេខ : ៧១៥ / សហវ.ប្រក.សហវ.កសក

ប្រកាសរួម

ស្តីពីការកែសម្រួលប្រការ ២ នៃប្រកាស លេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ថ្លៃសួយសារឈើយកឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យទាំងឡាយដែលដំឡើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុក្រឹត្យទាំងឡាយដែលដំឡើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

/៖

-បានឃើញប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីការកំណត់ថ្លៃសួយសារឈើយរឡើងវិញ ដើម្បីបង់ចំណូលថវិកាជាតិ

-បានឃើញការចាំបាច់

ស ម្រេ ច

ប្រការ១ : ត្រូវបានកែសម្រួលប្រការ ២ នៃប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីការកំណត់ថ្លៃសួយសារឈើយរឡើងវិញ ដើម្បីបង់ចំណូលថវិកាជាតិ ដូចខាងក្រោម :

ប្រការ២ថ្មី: ចំពោះសម្បទានដីសេដ្ឋកិច្ចត្រូវធ្វើការវាយតម្លៃប៉ាន់ស្មានធនធានផល អនុផលព្រៃឈើតាមអនុតំបន់ដែលអនុញ្ញាតឱ្យឈូសឆាយជាមុន និងអនុវត្តតាមនីតិវិធីដូចខាងក្រោម :

-ក្រុមហ៊ុនត្រូវដាក់ពាក្យសុំធ្វើការឈូសឆាយតាមអនុតំបន់ដែលបានកំណត់ក្នុងផែនការមេ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យបានយ៉ាងតិចបំផុតក្នុងរយៈពេល ០៤ ខែ មុនកាលកំណត់ចាប់ផ្ដើមឈូសឆាយ

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងពិនិត្យផ្ដល់គោលការណ៍អនុញ្ញាតឱ្យឈូសឆាយក្នុងរយៈពេលមិនលើសពីមួយខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំរបស់ក្រុមហ៊ុន

-រដ្ឋបាលព្រៃឈើនឹងសហការជាមួយក្រុមហ៊ុនធ្វើការវាយតម្លៃធនធានផល អនុផលព្រៃឈើ ដែលមានក្នុងអនុតំបន់ដែលទទួលគោលការណ៍សម្រេចអនុញ្ញាតឱ្យឈូសឆាយឱ្យចប់ក្នុងរយៈពេល ០៣ ខែ គិតចាប់ពីថ្ងៃទទួលបានការសម្រេចជាគោលការណ៍ឱ្យឈូសឆាយ

-ចំពោះឈើដែលបានមកពីការឈូសឆាយ ក្រុមហ៊ុនត្រូវរៀបចំប្រមូល និងរៀបចំដាក់ជាគំនរ ដើម្បីសហការជាមួយរដ្ឋបាលព្រៃឈើចុះធ្វើការវាស់វែង និងត្រូវបង់ថ្លៃសួយសារ និងបុព្វលាភជូនរដ្ឋតាមនីតិវិធីមុននឹងយកទៅប្រើប្រាស់ ។

សម្រាប់អនុតំបន់ដែលបានទទួលគោលការណ៍អនុញ្ញាតពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យឈូសឆាយមុនប្រកាសនេះចូលជាធរមាន អាចបន្តអនុវត្តទៅតាមគោលការណ៍ដែលបានសម្រេចរួចហើយនោះ ។

ប្រការ២ : អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ចាន់ សារុន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័នកណ្ដាល
-ដូចប្រការ២
-គ្រប់សាលាខេត្ត-រាជធានី
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៧១៨....សហវ...

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០

ប្រកាស

ស្ដីពី

ការបង្កើតគណៈកម្មការអន្តរក្រសួង សម្របសម្រួលការងារជួសជុល ថែទាំផ្លូវជនបទ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានការប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការ បង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០អនក្រ.បកចុះថ្ងៃទី២៩

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ខែមិនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងអភិវឌ្ឍន៍ជនបទ

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលស្តីពីនីតិវិធីនៃការបើកផ្តល់មុនដោយអាណត្តិបើកប្រាក់ សំរាប់ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់

-បានឃើញតំរូវការចាំបាច់ការងារ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "កសហវ" និង ក្រសួងអភិវឌ្ឍន៍ជនបទ "កអជ" ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **វង្សី វិស្សុត** អគ្គលេខាធិការ កសហវ	សហប្រធាន
២-ឯកឧត្តម **ហួត សារីម** អនុរដ្ឋលេខាធិការ កអជ	សហប្រធាន
៣-លោក **យិន សុផល** ប្រធាននាយកដ្ឋានផ្លូវជនបទ កអជ	អនុប្រធាន
៤-លោក **ចាន់ សុធី** ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ កសហវ	អនុប្រធាន
៥-លោកបណ្ឌិត **អៀង សុនលី** ប្រធាននាយកដ្ឋានហិរញ្ញកិច្ច កសហវ	អនុប្រធានប្រចាំការ
៦-លោក **ឆាន សុម៉ារ៉ា** ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ កអជ	សមាជិក
៧-លោក **ម៉ា សុវណ្ណា** ប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ កអជ	សមាជិក
៨-លោក **នួច សុខសម្បត្តិ** អនុប្រធានទី១ នាយកដ្ឋានហិរញ្ញកិច្ច កសហវ	សមាជិក
៩-លោក **មាស ចាន់ដេត** អនុប្រធាននាយកដ្ឋានថវិកា កសហវ	សមាជិក
១០-លោកបណ្ឌិត **ញី ហេង** អនុប្រធាននាយកដ្ឋានផ្លូវជនបទ កអជ	សមាជិក
១១-ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអភិវឌ្ឍន៍ជនបទ	លេខាធិការ

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចសម្របសម្រួលការងារជួសជុល ថែទាំផ្លូវជនបទ ដូចខាងក្រោម :

-កំណត់គោលការណ៍ និង គោលនយោបាយជួសជុល ថែទាំផ្លូវ ។

-រៀបចំផែនការជួសជុល ថែទាំផ្លូវ ។

-ធ្វើការតំរែតំរង់ទិស និង ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការថែទាំផ្លូវ ។

-រៀបចំគោលនយោបាយ និង ផែនការ សំរាប់តាមដាន និង ត្រួតពិនិត្យការថែទាំផ្លូវ ។

ប្រការ ៣ : គណៈកម្មការនេះ ត្រូវជួបប្រជុំរៀងរាល់ពីរខែម្តង នៅសប្តាហ៍ទី១ ដើមខែ និង ជួបប្រជុំតាមការចាំបាច់ដែលស្នើឡើងដោយក្រសួងណាមួយក្នុងចំណោមក្រសួងទាំងពីរ ។

ប្រការ ៤ : អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងអភិវឌ្ឍន៍ជនបទ និង ដូចប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ក្រសួងអភិវឌ្ឍន៍ជនបទ

ជា សុផារ៉ា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល :

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត-ក្រុង

"**ដើម្បីជ្រាប**"

-ដូចប្រការ ១ "**ដើម្បីអនុវត្ត**"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧៦៩ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០

ប្រកាស
ស្តីពី
ការបង្កើតគណៈកម្មការអន្តរក្រសួង សម្របសម្រួលការងារជួសជុល-ថែទាំប្រព័ន្ធធារាសាស្ត្រ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០អនក្រ.បកចុះថ្ងៃទី២៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ខែមិនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៨អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងធនធានទឹក និងឧតុនិយម

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលស្តីពីនីតិវិធីនៃការបើកផ្តល់មុនដោយអាណត្តិបើកប្រាក់ សំរាប់ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់

-បានឃើញតំរូវការចាំបាច់ការងារ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "កសហវ" និង ក្រសួងធនធានទឹក និងឧតុនិយម "ធទឧ" ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **ទន្សី ទិស្សុត** អគ្គលេខាធិការ កសហវ	សហប្រធាន
២-ឯកឧត្តម **ឯម ម៉ិនចឿន** អនុរដ្ឋលេខាធិការ ធទឧ	សហប្រធាន
៣-លោក **ចា ឈុនគៀត** ប្រធាននាយកដ្ឋានផែនការនិងសហប្រតិបត្តិការអន្តរជាតិ ធទឧ	អនុប្រធាន
៤-លោក **ចាន់ សុធី** ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ កសហវ	អនុប្រធាន
៥-លោកបណ្ឌិត **អៀង ស៊ុនលី** ប្រធាននាយកដ្ឋានហិរញ្ញកិច្ច កសហវ	អនុប្រធានប្រចាំការ
៦-លោក **មុយ មុនិន្ទ** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ធទឧ	សមាជិក
៧-លោក **លឹម ទីរៀ** ប្រធាននាយកដ្ឋានវិស្វកម្ម ធទឧ	សមាជិក
៨-លោក **ស៊ីខ សុផល** ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ធទឧ	សមាជិក
៩- លោក **នួច សុខសម្បត្តិ** អនុប្រធានទី១ នាយកដ្ឋានហិរញ្ញកិច្ច កសហវ	សមាជិក
១០-លោក **មាស ចាន់ដេត** អនុប្រធាននាយកដ្ឋានថវិកា កសហវ	សមាជិក
១១-ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងធនធានទឹក និងឧតុនិយម	លេខាធិការ

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចសម្របសម្រួលការងារជួសជុល ថែទាំប្រព័ន្ធធារាសាស្ត្រដូចខាងក្រោម :

-កំណត់គោលការណ៍ និង គោលនយោបាយជួសជុល ថែទាំ។

-រៀបចំផែនការជួសជុល ថែទាំ។

-ធ្វើការតំរែតំរង់ទិស និង ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការថែទាំ ។

-រៀបចំគោលនយោបាយ និង ផែនការ សំរាប់តាមដាន និង ត្រួតពិនិត្យការថែទាំ ។

ប្រការ ៣ : គណៈកម្មការនេះ ត្រូវជួបប្រជុំទៀងរាល់ពីរខែម្តង នៅសប្តាហ៍ទី១ ដើមខែ និង ជួបប្រជុំតាមការចាំបាច់ដែលស្នើឡើងដោយក្រសួងណាមួយក្នុងចំណោមក្រសួងទាំងពីរ ។

ប្រការ ៤ : អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងធនធានទឹកឧតុនិយម និង ដូចប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល :

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត-ក្រុង

"**ដើម្បីជ្រាប**"

-ដូចប្រការ ១ "**ដើម្បីអនុវត្ត**"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣៣ សហវ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ១២០ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល ប្រកាស លេខ ២១៨ សហវ ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើត គណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងលើភាពចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

សម្រេច

ប្រការ១ -

បង្កើត **"ក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស"** ហៅកាត់ **" កគជ "** ជាសេនាធិការនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងជាចំណុចប្រមូលផ្តុំសម្រាប់ការគ្រប់គ្រងជំនួយបច្ចេកទេសក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ប្រការ២.-

" កគជ " មានសមាសភាពដូចខាងក្រោម ៖

- អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ប្រធាន
- ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	អនុប្រធានប្រចាំការ
- អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួង ឬតំណាង	សមាជិក
- អគ្គាធិការនៃអគ្គាធិការដ្ឋាន	សមាជិក
- ប្រធាននាយកដ្ឋានចំណុះក្រសួង	សមាជិក
- នាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
- ប្រធានអង្គភាពគ្រប់គ្រងសាច់ប្រាក់	សមាជិក

ប្រការ៣. –

"កគជ " មានភារកិច្ចគ្រប់គ្រង និងសម្របសម្រួលការប្រើប្រាស់ជំនួយបច្ចេកទេស ឲ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីគាំទ្រដល់ការរៀបចំ និងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងត្រូវបំពេញតួនាទី ការទទួលខុសត្រូវ ព្រមទាំងសិទ្ធិអំណាច ដូចមានចែងក្នុងលក្ខខណ្ឌយោងនៃក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

ប្រការ៤. –

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០១០

ចំលងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៤៩......... ប្រក.កសក

ជាថិតចម្លង
ថ្ងៃទី០៣...ខែតុលា...ឆ្នាំ២០១...

ប្រកាស
ស្តីពី
ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកែប

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ

អាគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

សម្រេច

ប្រការ ១.-

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកែប សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើកែប នៃខណ្ឌរដ្ឋបាលព្រៃឈើកំពត ។

ប្រការ ២.-

ការបង្កើតតំបន់ព្រៃសហគមន៍ក្នុងគោលបំណង ៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍព្រៃសហគមន៍ឱ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណី សម្រាប់ការរស់នៅ ទំនៀមទម្លាប់ និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមសក្តានុពល និង លទ្ធភាពធនធានព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

ប្រការ ៣.-

តំបន់ព្រៃសហគមន៍ក្នុងខេត្តកែបនៃប្រកាសនេះមាន ០១ សហគមន៍ព្រៃឈើ ចែកចេញជា ០១ កន្លែង ដែលមានផ្ទៃដីសរុបចំនួន ៦០ (ហុកសិប)ហិកតា ដូចមានក្នុងផែនទី ទីតាំងព្រៃសហគមន៍ និង ផែនទីសហគមន៍នីមួយៗ ភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និង ជាប្រព័ន្ធខ្សែព្រំប្រទដិត កំណត់ដោយចំណុចគោល និង និយាមកា ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

ប្រការ ៤.-

ដំណើរការរៀបចំ និង ការប្រព្រឹត្តិទៅនៃសហគមន៍ព្រៃឈើ នៅក្នុងតំបន់ព្រៃសហគមន៍ដែលបានកំណត់ក្នុងប្រកាសនេះត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និង ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

ប្រការ ៥.-

ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយដ្ឋានផែនការនិងស្ថិតិ ប្រធានមន្ទីរកសិកម្មខេត្តកែប និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ចន្ទ សារុន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកែប
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ១ : ប្រកាសលេខ .... ប្រក.កសក ចុះថ្ងៃទី .... ខែ .... ឆ្នាំ ....

ទីតាំងព្រៃសហគមន៍ក្នុងខេត្តកែប



ឧបសម្ព័ន្ធ ២ ៖ ភ្ជាប់ប្រកាសលេខ ៥៤៤៨ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០

ទីតាំងព្រៃសហគមន៍ក្នុងខេត្តកែប

លរ	ឈ្មោះសហគមន៍	ផ្ទៃដី (ហិកតា)	និយាមកា UTM								ភូមិ	ឃុំ	ស្រុក	ផ្នែករដ្ឋបាលព្រៃឈើ
			កំណត់បណ្ដាញប្រឹថពីវិភាគ ឥណ្ឌា ១៩៦០											
១	ភ្នំពោន	៦០	កើត	A	429683	1161668	B	429834	1160888		១	ពងទឹក	ដំណាក់ចង្អើរ	កែប
			ត្បូង	B	429834	1160888	C	429482	1160384					
			លិច	C	429482	1160384	D	429113	1160830					
			ជើង	D	429113	1160830	E	429086	1161928					
				E	429086	1161928	A	429683	1161668					
សរុប		៦០									១	១	១	

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ..៤៩......សសរ-អកគដ

សេចក្តីសម្រេច
ស្តីពី
ការដាក់ឱ្យប្រើប្រាស់គំរូឧបសម្ព័ន្ធ ដើម្បីអនុវត្តសារាចរស្តីពីការដោះស្រាយ សំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានឧទ្ទានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើ ច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ

១/៤

- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញប្រកាសលេខ ៤២ ដនស បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

ស ម្រេ ច

ប្រការ ១: ដាក់ឱ្យប្រើប្រាស់គំរូឯកសារចំនួន ១៣ ដូចខាងក្រោម ជាឧបសម្ព័ន្ធ នៃសារាចររាជរដ្ឋាភិបាលលេខ ០៣ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន :

១- គំរូតារាងទិន្នន័យទីតាំងសំណង់បណ្តោះអាសន្ន តាមឃុំ សង្កាត់ **(ឧបសម្ព័ន្ធ០១)**

២- គំរូតារាងស្ថិតិរួម នៃទីតាំងសំណង់បណ្តោះអាសន្នក្នុងក្រុង ស្រុក ខណ្ឌ **(ឧបសម្ព័ន្ធ០២)**

៣- គំរូតារាងស្ថិតិរួម នៃទីតាំងសំណង់បណ្តោះអាសន្នក្នុងរាជធានី ខេត្ត **(ឧបសម្ព័ន្ធ០៣)**

៤- គំរូផែនទី ទីតាំងសំណង់បណ្តោះអាសន្នតាមឃុំ សង្កាត់ និងសេចក្តីព្រាងប្លង់ទីតាំងនីមួយៗ **(ឧបសម្ព័ន្ធ០៤)**

៥- គំរូរបាយការណ៍ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងកាធ្វើចំណាត់ថ្នាក់ដីរដ្ឋ លើទីតាំងសំណង់បណ្តោះអាសន្ននៅក្នុងក្រុង ស្រុក ខណ្ឌ **(ឧបសម្ព័ន្ធ០៥)**

៦- គំរូបញ្ជីឈ្មោះគ្រួសារ ដែលបានកាន់កាប់ទីតាំងសំណង់បណ្តោះអាសន្នតាមទីតាំង និងសមាជិកគ្រួសារនីមួយៗតាមទីតាំង **(ឧបសម្ព័ន្ធ០៦)**

៧- គំរូសេចក្តីសង្ខេបមតិសាធារណៈ **(ឧបសម្ព័ន្ធ០៧)**

៨- គំរូរបាយការណ៍នៃការប្រជុំក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ស្តីពីការស្វែងរកដំណោះស្រាយលើទីតាំងសំណង់បណ្តោះអាសន្ន និងបញ្ជីគ្រួសារទទួលយកដំណោះស្រាយ **(ឧបសម្ព័ន្ធ០៨)**

៩- គំរូសេចក្តីជូនដំណឹង ស្តីពីដំណោះស្រាយទីតាំងសំណង់បណ្តោះអាសន្ន និងបញ្ជីភ្ជាប់ **(ឧបសម្ព័ន្ធ០៩)**

១០-គំរូកិច្ចសន្យាផលុបភោគ **(ឧបសម្ព័ន្ធ១០)**

១១-គំរូកិច្ចសន្យាសម្រាប់ផ្តល់សិទ្ធិកម្មសិទ្ធិ **(ឧបសម្ព័ន្ធ១១)**

១២-គំរូកិច្ចសន្យាជួលមានរយៈពេលកំណត់ **(ឧបសម្ព័ន្ធ១២)**

១៣-គំរូបញ្ជីវត្តមានអ្នកចូលរួមកិច្ចប្រជុំនានា **(ឧបសម្ព័ន្ធ១៣)**

ប្រការ ២: សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី

អ៊ឹម ឈុនលឹម

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ១
នៃសេចក្តីសម្រេចលេខ ៤៥ សសរ-អគគជ
ចុះថ្ងៃទី ២៧ ខែ កញ្ញា ២០១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូតារាងចិន្ដនំយទីតាំងសំណង់បណ្ដោះអាសន្នតាមឃុំ សង្កាត់

រាជធានី ខេត្ត ....
ក្រុង ស្រុក ខណ្ឌ ....
ឃុំ សង្កាត់ ....

